# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៦៤ . សសរ

## សេចក្តីសំរេច
ស្តីពី
ការបង្កើតគណៈកម្មការពិនិត្យ វាយតំលៃ និងជ្រើសរើសក្រុមហ៊ុនទីប្រឹក្សាបច្ចេកទេស និងក្រុមហ៊ុនសាងសង់ផ្លូវជាតិលេខ ៥ និង ៦ (ប៉ោយប៉ែត-សៀមរាប) និងផ្លូវលេខ ៥៦ និង ៦៨ (ស៊ីសូផុន-សំរោង-ក្រឡាញ់)

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមតំរូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ១ :** បង្កើតគណៈកម្មការអន្តរក្រសួង សំរាប់ជ្រើសរើសក្រុមហ៊ុនទីប្រឹក្សាបច្ចេកទេសត្រួតពិនិត្យការងារសាងសង់ និងជ្រើសរើសក្រុមហ៊ុនសាងសង់ផ្លូវជាតិលេខ ៥ និង ៦ (ប៉ោយប៉ែត-សៀមរាប) និងផ្លូវលេខ ៥៦ និង ៦៨ (ស៊ីសូផុន-សំរោង-ក្រឡាញ់) ក្រោមហិរញ្ញប្បទាន នៃឥណទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដោយមានសមាសភាព ដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **ត្រាំ អ៊ីវតឹក** | រដ្ឋលេខាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន | ប្រធាន |
| ២-ឯកឧត្តម | **ឈិន គង់ហ៊ាន** | អគ្គនាយកសាធារណការ ក្រសួងសាធារណការ និងដឹកជញ្ជូន | អនុប្រធាន |
| ៣-ឯកឧត្តម | **ចន្ធី វិស្សុត** | អគ្គលេខាធិការរង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៤-លោក | **ទី ស៊ីមសុរិយា** | ប្រធាននាយកដ្ឋានផែនការ ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ៥-លោក | **រស់ ប៊ុរម** | អនុប្រធាននាយកដ្ឋានវិនិយោគនិងសហប្រតិបត្តិការ សហវ. | សមាជិក |
| ៦-លោក | **ផែង សុទិដ្ឋារនោ** | មន្ត្រីគំរោង ADB ក្រសួងសាធារណការនិងដឹកជញ្ជូន | សមាជិកអចិន្ត្រៃយ៍ |
| ៧-លោក | **ឃុន សុខា** | មន្ត្រី នៃក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |

**ប្រការ២ :** គណៈកម្មការនេះ មានភារកិច្ចរៀបចំការកំណត់នូវគោលការណ៍ សំរាប់ពិនិត្យ វាយតំលៃ ដើម្បីធ្វើការជ្រើសរើសក្រុមហ៊ុនទីប្រឹក្សាបច្ចេកទេស និងក្រុមហ៊ុនសាងសង់ ប្រកបដោយភាពរលូន និងមានលក្ខណៈត្រឹមត្រូវ ដោយផ្អែកតាមគោលការណ៍របស់ធនាគារអភិវឌ្ឍន៍អាស៊ី ។

**ប្រការ៣ :** ប្រធានគណៈកម្មការ មានសិទ្ធិកោះប្រជុំសមាជិករបស់ខ្លួន ដើម្បីពិភាក្សាលើបញ្ហាពាក់ព័ន្ធនានា ។ នាយកគំរោង មានភារកិច្ចធ្វើទំនាក់ទំនងជាមួយធនាគារអភិវឌ្ឍន៍អាស៊ី តាមការឯកភាពរបស់ប្រធានគណៈកម្មការ ។

**ប្រការ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និងសាមីខ្លួនដែលមានចែងក្នុងប្រការមួយ ត្រូវអនុវត្តសេចក្តីសំរេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០០៣*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ✓
- ដូចចែងក្នុងប្រការ ៤
- ឯកសារ-កាលប្បវត្តិ